# KHMER- ការបំបៅដោះនៅក្នុងសប្តាហ៍ដំបូងគឺសំរាប់ទារកទាំងពួងឲ្យប្រកបដោយសុខភាពដ៏ល្អពេញលេញ៖ អ្វីដែលអ្នកត្រូវការចង់ដឹង

MonashWomen's
MonashHealth

## (Breastfeeding in the first week for healthy full term babies: What you need to know)

**ទារកទាំងឡាយមានភាពខុសៗគ្នា។ ប្រសិនជាមានភាពព្រួយបារម្ភពីអ្វីមួយនោះ ចូរពិភាក្សាជាមួយឆ្មបរបស់អ្នក**

| | **ពេល 24 ម៉ោងដំបូង** | **ថ្ងៃទី 2**<br>**(24 ទៅ 48ម៉ោង)** | **ថ្ងៃទី 3**<br>**(48 ទៅ 72 ម៉ោង)** | **ថ្ងៃទី 4**<br>**(លើសពី 72 ម៉ោង)** | **ថ្ងៃទី 4 ទៅថ្ងៃទី 6** | **ថ្ងៃទី 7** |
|---|---|---|---|---|---|---|
| **ដោះទាំងពីរ** | នៅទន់ | នៅទន់ | បន្ទាប់មកទឹកដោះឡើងពេញហើយឡើងរឹង។ សរសៃឡើងនៅលើដោះអាចមើលឃើញច្បាស់។ | ដោះទាំងពីរឡើងពេញហើយឡើងរឹងផង។ | ទឹកដោះឡើងពេញទៅជាទន់ដោយការបំបៅដោះច្រើនដង។ | ទឹកដោះឡើងពេញ ទៅជាទន់ដោយ ការបំបៅដោះច្រើនដង។ |
| **ទឹកដោះ** | កូឡូស្រ្ទម **(Colostrum) -** មានចំនួនដ៏តិច ដោយមាននូវជីវជាតិជាច្រើន លឿខាប់ថ្លា ពណ៌ទឹកក្រូច ប្រហែល **1/2** ទៅ **1** កូនស្លាបព្រាពេលបំបៅ ម្តង។ | កូឡូស្រ្ទម **(Colostrum)** ប្រហែល **1** ទៅ **2** កូនស្លាបព្រាពេលបំបៅម្តង។ | ទឹកដោះចាប់ផ្តើមមានហូរចេញមកពណ៌ស | ទឹកដោះមាន សំបូរកាន់តែច្រើន | ពណ៌កាន់តែ ស | សំបូរកាន់តែច្រើនទៅតាមភាពតម្រូវការ។ |
| **ទារក** | ដោយដាក់ផ្ទប់ស្បែកទារកទៅ នឹងស្បែកម្តាយ ចាប់ពីពេលកើត ការចាប់ផ្តើមបំបៅនៅពេល **2** ម៉ោងដំបូង។ បន្ទាប់បំបៅលើកដំបូងរួច មកទារកអាចគេងចាប់ពី **4** ទៅ **6** ម៉ោងឬ ឆាប់ភ្ញាក់ នឹងត្រូវការបំបៅ ជាញឹកញាប់ផងដែរ។ | ធម្មតាទារក តែងមានភាពជាសកម្មយ៉ាងមម៉ាញឹក នឹងច្រើនតែភ្ញាក់។ ជាញឹកញាប់ទារកភ្ញាក់យំមិនគេង ជាពិសេសនៅពេលយប់។ ភាគច្រើនបាត់យំហើយគេង នៅពេលលើកមកឱបក្រសោប ដោយដាក់ផ្ទប់ស្បែកទារកទៅនឹងស្បែកម្តាយ។ | ទារកភាគច្រើនតែងនៅបន្តការភ្ញាក់នឹងបៅច្រើនជាញឹកញាប់ ជាពិសេសនៅពេលយប់។<br><br>ពេលខ្លះទៀតទារកគេងលក់ដ៏យូរនៅរវាងពេលបៅរួចម្តងៗ។ | ទារកភាគច្រើននៅតែបន្តការភ្ញាក់ ហើយបៅជាញឹកញាប់។ ទារកអាចបឺតជញ្ជក់ហើយ លេបចូល ក្នុងរវាង **2** ទៅ **3**នាទីបន្ទាប់មកសំរាកការបឺតដល់ ទៅ **30**វិនាទីរួចហើយ ក៏ចាប់ផ្តើមបឺតជញ្ជក់ជាបន្តទៀត៖ រួចលេបចូលដូចជាលំនាំដដែលឡើងវិញ។ | ទារកបៅច្រើនញឹកញាប់នៅពេលយប់ នឹងគេងបានច្រើននៅពេលថ្ងៃ។ | ការបំបៅច្រើនតម្រូវទៅតាមការឃ្លានរបស់ទារកដែលធ្វើឲ្យរាងកាយអ្នកផលិតចេញទឹកដោះបានយ៉ាងច្រើនទៅតាមចំនួនត្រូវការរបស់ទារកអ្នក។ |

**KHMER- ការបំបៅដោះនៅក្នុងសប្តាហ៍ដំបូងគឺសំរាប់ទារកទាំងឡាយឲ្យប្រកបដោយសុខភាពដ៏ល្អពេញលេញ៖ អ្វីដែលអ្នកត្រូវការចង់ដឹង**

MonashWomen's MonashHealth

**(Breastfeeding in the first week for healthy full term babies: What you need to know)**

**ទារកទាំងឡាយមានភាពខុសៗគ្នា។ ប្រសិនជាមានភាពព្រួយបារម្ភពីអ្វីមួយនោះ ចូរពិភាក្សាជាមួយឆ្មបរបស់អ្នក**

| | **ពេល 24 ម៉ោងដំបូង** | **ថ្ងៃទី 2**<br>**(24 ទៅ 48ម៉ោង)** | **ថ្ងៃទី 3**<br>**(48 ទៅ 72 ម៉ោង)** | **ថ្ងៃទី 4**<br>**(លើសពី 72 ម៉ោង)** | **ថ្ងៃទី 4 ទៅថ្ងៃទី 6** | **ថ្ងៃទី 7** |
|---|---|---|---|---|---|---|
| **ការបំបៅដោះ ទារកនឹងចំនួននៃការច្របាច់យកទឹកដោះ ប្រសិនបើ ជាទារកមិនទាន់មានសកម្មភាពក្នុងការបំបៅដោះបាន។** | ការបំបៅបានយ៉ាងតិចណាស់ក៏បាន **3** ទៅ **4** ដង ហើយឬក៏ច្របាច់យកទឹកដោះទុកបំបៅដែលអាចនឹងធ្វើទៅបានច្រើនដងផង។<br>ចូរបំបៅដោះទាំងពីរនឹងដាក់ដោយផ្ទប់ស្បែកកូនទៅនឹងស្បែកម្តាយ។ ទារកលេបចូលបន្ទាប់ពីបឺតជញ្ជក់បានមួយចំនួន។ ការច្របាច់យកទឹកដោះដោយដៃ បើសិនជាទារកមិនអាចបឺតជញ្ជក់បាន។ | ការបំបៅពី **6**ដងឬលើសពី **8** ដង ហើយ/ ឬច្របាច់យកទឹកដោះ។ បំបៅជាញឹកញយបង្កើនទឹកដោះឲ្យមានកាន់តែច្រើនឡើង។ ជាញឹកញយដោយបំបៅទារកពី **1** ទៅ **3** ម៉ោង រួចឈប់ សំរាកពី **2**ទៅ **3** ម៉ោង។ ត្រូវការពេលច្រើនក្នុងការដាក់ ផ្ទប់ស្បែកកូនទៅនឹងស្បែកម្តាយ។ ការច្របាច់យកទឹកដោយដៃ ប្រសិនជាទារកមិនអាចជញ្ជក់បាន។ | ការបំបៅពី **8** ទៅ**12**ដង ហើយឬច្របាច់យកទឹកដោះ។ ឮសំឡេងការបឺតជញ្ជក់នឹងការលេបចូល។ បំបៅម្តងទៀត ប្រសិនជាទារកនៅតែយំ។ ត្រូវការពេលច្រើនក្នុងការដាក់ផ្ទប់ស្បែកកូនទៅនឹង ស្បែកម្តាយ។<br>ការច្របាច់យកទឹកដោះដោយដៃ បើសិនជាទារកមិនអាចជញ្ជក់បាន។ | ការបំបៅពី **8** ទៅ**12** ដង ហើយ/ ឬ ច្របាច់យកទឹកដោះ។ ចំនួនជាមធ្យមសំរាប់ការបំបៅដោះ **11** ដង ក្នុង **24** ម៉ោងអាចប្រើ ម៉ាស៊ីនខ្សែភ្លើងបូមដោះ បើសិនជាត្រូវការបូមយកទឹកដោះ។ | ការបំបៅពី **8** ទៅ **12** ដង ហើយ/ ឬ ច្របាច់យកទឹកដោះ។ អាចឃើញ ឬ ឮសូសំឡេងក្នុង ការលេបចូល។ បំបៅចាប់ពីដោះ ម្ខាងរហូតទាល់តែធូរស្រួល ហើយ/ រួចប្តូរទៅដោះម្ខាងទៀតដោយយោងទៅតាមសញ្ញា **cues** នៃការបៅរបស់ទារក។ | ការបំបៅពី **8** ទៅ**12** ដងហើយ/ ឬ ច្របាច់យកទឹកដោះ។<br>ដោយយោងទៅតាមសញ្ញា **cues** នៃការបៅរបស់ទារក។<br>ការគេងអោបបំបៅនៅពេលថ្ងៃនឹងពេលល្ងាចគឺជាភាពធម្មតា។ |
| **ការជុះនោម** | យ៉ាងតិចក៏កន្ទបទទឹកអស់ **1**ដៃរ។ | យ៉ាងតិចក៏កន្ទបទទឹកអស់ **2** ដៃរ។ | យ៉ាងតិចក៏កន្ទបទទឹកអស់ **2** ទៅ **3** ដៃរ។<br>មានពណ៌ផ្កាឈូកឬពណ៌ទឹកក្រូចប្រលាក់ជាមលើកន្ទបគឺជាភាពធម្មតា។ | យ៉ាងតិចក៏កន្ទបទទឹកអស់ **3** ទៅ **4** មានពណ៌ស្រាល។ កន្ទបទាំងប៉ុន្មានធ្ងន់ទទឹកជោគ។ | យ៉ាងតិចក៏កន្ទបទទឹកអស់ **4** ទៅ **6** មានពណ៌ស្រាល។ កន្ទបទាំងប៉ុន្មានធ្ងន់ទទឹកជោគ។ | យ៉ាងតិចក៏កន្ទបទទឹកអស់ **6** មានពណ៌ស្រាល។ កន្ទបទាំងប៉ុន្មានធ្ងន់ទទឹកជោគ។ |
| **ការជុះលាមក** | យ៉ាងតិចក៏ជុះ **1** ដង មានលាមកក្រាស់ស្អិតខ្មៅ នឹងពណ៌បៃតង។ | យ៉ាងតិចក៏ជុះ **2** ដង មានពណ៌ខ្មៅ នឹង ពណ៌បៃតងមិនសូវស្អិត។ | យ៉ាងតិចក៏ជុះ **3** ដង មានលាមកឡើងជ្រាយពណ៌បៃតងនឹងពណ៌ត្នោត។ | លាមកឡើងជ្រាយឬរាគជាមានពណ៌ត្នោតឬលឿង។ | ជាញឹកញាប់ (អាចនឹងមាននៅពេលបំបៅម្តងៗ)។ រាគជាទឹកផុកៗ ពណ៌លឿងមានដុំតូចៗផង។ | ជាញឹកញាប់យ៉ាងតិចក៏ជុះ **2** ដងក្នុងមួយ ថ្ងៃ រាគជាទឹកឬផុកៗ ពណ៌លឿងមានដុំតូចៗផង។ |